**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**

ជាន់ទី១២ អាគារ Exchange Square
ផ្លូវលេខ១០៦ កែងផ្លូវលេខ៦១
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

AIA.COM.KH

# សេចក្តីប្រកាសសារព័ត៌មាន

## ដំណោះស្រាយធានារ៉ាប់រងជីវិតដ៏ទូលំទូលាយបំផុតនៅកម្ពុជា៖
## អេ អាយ អេ ខេមបូឌា បន្ថែមការការពាររហូតដល់២៦ស្ថានភាពជំងឺធ្ងន់ធ្ងរ ដោយឥតគិតថ្លៃ

**រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩** – អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") បានប្រកាសបន្ថែមការការពារចំពោះ AIA សម្រាប់ជីវិត ដែលជាដំណោះស្រាយធានារ៉ាប់រងជីវិតឈានមុខគេនៅកម្ពុជា ក្នុងឱកាសប្រារព្ធខួប១00ឆ្នាំរបស់សម្ព័ន្ធ AIA Group Limited ("AIA") ។ AIA សម្រាប់ជីវិត គឺជាដំណោះស្រាយធានារ៉ាប់រងជីវិតដំបូងគេបង្អស់ក្នុងកម្ពុជាតាំងពីខែឧសភា ឆ្នាំ២០១៧ ផ្តល់ការការពារលើជំងឺធ្ងន់ធ្ងរជាច្រើនពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយដូចជា ជំងឺមហារីក ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺថ្លើម ជំងឺសួត និងជំងឺបេះដូង។ ឥឡូវនេះ ក្រុមហ៊ុនបានបង្កើនការការពារលើជំងឺតម្រងនោម និងការប្តូរសរីរាង្គសំខាន់ៗ ដែលរួមមានលំពែងផងដែរ សរុបដល់ទៅ២៦លក្ខខណ្ឌ។ ទាំងអតិថិជនបច្ចុប្បន្ន និងអតិថិជនថ្មី នឹងទទួលបានការធានារ៉ាប់រងបន្ថែមនេះ ដោយឥតគិតថ្លៃ។ ការបន្ថែមនេះ ធ្វើឲ្យ AIA សម្រាប់ជីវិត ក្លាយជាដំណោះស្រាយសម្រាប់ជំងឺធ្ងន់ធ្ងរ ដែលទូលំទូលាយបំផុតនៅកម្ពុជា។

អគ្គនាយកក្រុមហ៊ុន អេ អាយ អេ ខេមបូឌា លោក Richard Bates បានមានប្រសាសន៍ថា «ឆ្នាំ២០១៩ គឺជាខួប១00ឆ្នាំរបស់ AIA។ ដូច្នេះយើងមានមោទនភាពក្នុងការអបអរឱកាសនេះ ដោយការបន្ថែមការការពារចំពោះ AIA សម្រាប់ជីវិត ដែលជាដំណោះស្រាយធានារ៉ាប់រងជីវិតដំបូងបង្អស់សម្រាប់ជំងឺធ្ងន់ធ្ងរ ដើម្បីបន្តជំរុញការប្តេជ្ញាចិត្តរបស់យើងក្នុងការជួយប្រជាជនកម្ពុជាឲ្យទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ។» លោក Richard ក៏បានបន្តថា អតិថិជនយើងបច្ចុប្បន្ន អាចទទួលបានការការពារបន្ថែមនេះដោយមិនតម្រូវឲ្យមានការធ្វើបែបបទ ឬការពិនិត្យសុខភាពបន្ថែមឡើយ ដើម្បីផ្តល់ភាពងាយស្រួលជូនពួកគាត់ក្នុងការទទួលបានការការពារនៅពេលក្រោយ ក្នុងករណីគាត់មានជំងឺ។

ការបន្ថែមការការពារនេះ គឺក្នុងគោលបំណងឆ្លើយតបនឹងការកើនឡើងនៃជំងឺតម្រងនោម និងតម្រូវការសម្រាប់ការប្តូរសរីរាង្គនៅក្នុងប្រទេសកម្ពុជា។ យោងតាមទិន្នន័យរបស់អង្គការសុខភាពពិភពលោក (WHO) បានឲ្យដឹងថានៅឆ្នាំ២០១៧ មានអ្នកស្លាប់ជិត ២,៥00នាក់ ដោយសារជំងឺតម្រងនោម[១] ហើយការប្តូរតម្រងនោមគឺជា «ការផ្លាស់ប្តូរសរីរាង្គ ដែលត្រូវបានគេធ្វើឡើងច្រើនជាងគេបំផុតលើពិភពលោក។»[២]

ការព្យាបាលជំងឺតម្រងនោម អាចមានតំលៃរាប់សិបពាន់ដុល្លារ ហើយអាចត្រូវការការព្យាបាលដោយការលាងសារធាតុពុលក្នុងឈាមជាទៀងទាត់។ ដូចគ្នានេះផងដែរ នៅក្នុងប្រទេសកម្ពុជា ចំនួនអ្នកឯកទេសផ្នែកតម្រងនោម និងឧបករណ៍បច្ចេកទេសចាំបាច់ ក៏នៅមានកម្រិតនៅឡើយ។ កត្តាទាំងនេះ បង្ហាញថាការមានដំណោះស្រាយធានារ៉ាប់រងទូលំទូលាយមួយ គឺមានសារៈសំខាន់ណាស់ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺនេះដោយជោគជ័យ។

---

[១] World Life Expectancy (២០១៩). *Health profile: Cambodia.* ទាញយកនៅថ្ងៃទី១០ មករា ២០១៩ ពី https://www.worldlifeexpectancy.com/country-health-profile/cambodia

[២] World Health Organisation (២០១៩). *Human organ transplantation*. ទាញយកនៅថ្ងៃទី១០ មករា ២០១៩ ពី https://www.who.int/transplantation/organ/en/

ការព្យាបាលដ៏សំខាន់មួយសម្រាប់ជំងឺតម្រងនោមដំណាក់កាលចុងក្រោយ គឺការប្តូរសរីរាង្គតែម្តង ដែលឥឡូវត្រូវបានរ៉ាប់រងដោយ AIA សម្រាប់ជីវិត។ លើសពីនេះ ដំណោះស្រាយនេះក៏រ៉ាប់រងលើការផ្លាស់ប្តូរសរីរាង្គសំខាន់ៗដទៃទៀតផងដែរ ដែលនេះធ្វើឲ្យ AIA សម្រាប់ជីវិត ក្លាយជាដំណោះស្រាយដ៏មានឥទ្ធិពលសម្រាប់ការទទួលបានសុខភាពល្អឡើងវិញក្នុងករណីមានជំងឺធ្ងន់ធ្ងរ។

AIA សម្រាប់ជីវិត ក៏នឹងបន្តផ្តល់ជូនការធានារ៉ាប់រងលើការព្យាបាលជំងឺធ្ងន់ធ្ងរជាច្រើនផ្សេងទៀតដូចជា ជំងឺមហារីក ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺថ្លើម ជំងឺសួត និងជំងឺបេះដូង។ បើយោងតាមអង្គការសុខភាពពិភពលោក បច្ចុប្បន្នជំងឺធ្ងន់ធ្ងរទាំងនេះ មានអត្រាកើនឡើងខ្ពស់ ហើយចំនួនអ្នកបាត់បង់ជីវិតដោយសារជំងឺនេះ បានកើនឡើងដល់ទៅ៦៤ភាគរយនៃការស្លាប់សរុបប្រចាំឆ្នាំក្នុងប្រទេសកម្ពុជា។[៣]

ជាមួយនឹងការការពារបន្ថែមរបស់ AIA សម្រាប់ជីវិត ឥឡូវនេះប្រជាជនកម្ពុជាកាន់តែមានភាពងាយស្រួល និងអាចចំណាយថវិកាដោយមានប្រសិទ្ធិភាពកាន់តែខ្ពស់ ក្នុងការទទួលយកការការពារដ៏ទូលំទូលាយ មានជីវិតយូរអង្វែង និងពេញលេញ ដោយមិនចាំបាច់មានភាពតានតឹងផ្នែកហិរញ្ញវត្ថុប្រសិនបើពួកគាត់មានជំងឺនៅថ្ងៃក្រោយ។

**អំពី អេ អាយ អេ ខេមបូឌា**

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") គឺជាបុត្រសម្ព័ន្ធ និងជាកម្មសិទ្ធិទាំងស្រុងរបស់ AIA Group Limited ("AIA") ដែលជាសម្ព័ន្ធក្រុមហ៊ុនធានារ៉ាប់រងជីវិតធំជាងគេបំផុតនៅលើពិភពលោកដោយយោងតាមទីផ្សារមូលធននីយកម្ម។

សម្ព័ន្ធ AIA មានវត្តមាននៅក្នុងទីផ្សារចំនួន១៨នៅអាស៊ីប៉ាស៊ីហ្វិក ដែលក្នុងនោះមានសាខា និងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិទាំងស្រុង នៅហុងកុង ថៃ សិង្ហបុរី ម៉ាឡេស៊ី ចិន កូរ៉េ ហ្វីលីពីន អូស្ត្រាលី ឥណ្ឌូនេស៊ី តៃវ៉ាន់ វៀតណាម ណូវែលហ្សេឡង់ ម៉ាកាវ ប្រ៊ុយណេ កម្ពុជា ព្រមទាំងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិ៩៧ភាគរយនៅស្រីលង្កា ក្រុមហ៊ុនសម្ព័ន្ធអាជីវកម្ម៤៩ភាគរយនៅឥណ្ឌូនេស៊ី និងការិយាល័យតំណាងនៅមីយ៉ាន់ម៉ា។ AIA គឺជាក្រុមហ៊ុននាំមុខទីផ្សារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (លើកលែងជប៉ុន) ដោយយោងលើបុព្វលាភធានារ៉ាប់រងជីវិត និងជាក្រុមហ៊ុនឈានមុខគេនៅក្នុងទីផ្សារភាគច្រើនរបស់ខ្លួន។ AIA មានទ្រព្យសរុប២២១ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ តាមរយៈបណ្តាញដ៏ទូលំទូលាយនៃភ្នាក់ងារ ដៃគូ និងធនធានមនុស្សនានាទូទាំងអាស៊ីប៉ាស៊ីហ្វិក AIA បម្រើម្ចាស់បណ្ណសន្យាធានារ៉ាប់រងច្រើនជាង៣២លានបណ្ណ និងសមាជិកទទួលអត្ថប្រយោជន៍ធានារ៉ាប់រងតាមក្រុមហ៊ុននានាច្រើនជាង១៦លាននាក់។

អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយ និងសេវាកម្មធានារ៉ាប់រងជីវិតឈានមុខគេក្នុងទីផ្សារ ដើម្បីបំពេញតម្រូវការលើការការពារ និងការសន្សំរយៈពេលវែង របស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា។ អេ អាយ អេ ខេមបូឌា ប្តេជ្ញាចូលរួមលើកកំពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃព្រះរាជាណាចក្រកម្ពុជាឲ្យបានយូរអង្វែង និងជួយឲ្យប្រជាជនខ្មែរទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ។

**ទំនាក់ទំនងសារព័ត៌មាន**

ហាក់ បញ្ញារ័ត្ន
ប្រធានផ្នែកទំនាក់ទំនងសាធារណៈ
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
០១៦/០១៧ ៣៦៩ ១៥៥
Panharath.Hak@aia.com

[៣] World Health Organisation (២០១៩). *Cambodia*. ទាញយកនៅថ្ងៃទី១០ មករា ២០១៩ ពី https://www.who.int/nmh/countries/khm_en.pdf